គណៈប្រតិភូទីក្រុង Bacolod មកទស្សនកិច្ចសិក្សាប្តូរបទពិសោធន៍នៅសង្កាត់ទួលសង្កែ

គណៈប្រតិភូ BACOLOD និងក្រុមប្រឹក្សាសង្កាត់ទួលសង្កែថតរូបអនុស្សាវរីយ៍ និងប្តូរបទពិសោធន៍គ្នា

ភ្នំពេញ៖ នៅសាលាសង្កាត់ទួលសង្កែកាលពីព្រឹកថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១លោកសយ កុសលចៅសង្កាត់ទួលសង្កែនិងក្រុមប្រឹក្សាសង្កាត់ព្រមទាំងប៉ុស្តិ៍រដ្ឋបាលនគរបាលសង្កាត់ទួលសង្កែបានធ្វើពិធីទទួលស្វាគមន៍ដល់គណៈប្រតិភូមួយក្រុមដែលដឹកនាំដោយលោក Attyevelior leonerdia អភិបាលក្រុង Bacolod នៃប្រទេសហ្វីលីពីនដែលបានអញ្ជើញមកធ្វើទស្សនកិច្ចសិក្សាដើម្បីផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមកចំនួន៣ថ្ងៃអំពីភាពជាដៃគូរវាងវិស័យឯកជនប្រជាជនរដ្ឋបាលមូលដ្ឋាននិងរដ្ឋដែលបានអនុវត្តល្អគំរូល្អក្នុងចំណោមប្រទេសដែលអនុវត្តវិមជ្ឈការ។

ការផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមកនេះគឺមាន៥ប្រទេសនៅក្នុងតំបន់អាស៊ីដូចជាកម្ពុជាឥណ្ឌូនេស៊ី ថៃ វៀតណាមនិងហ្វីលីពីនដែលសំរបសំរួលដោយសហគមន៍អឺរ៉ុបនិងអង្គការខនរ៉ាត់ អាដេណៅអ៊ែរ ដែលមានភារកិច្ចផ្តល់ការអនុវត្តន៍ល្អគំរូល្អទៅដល់ក្រុមការងាររបស់ប្រទេសនីមួយៗដែលសហគមន៍អឺរ៉ុបធ្វើការជួបជុំគ្នាដើម្បីបោះឆ្នោតជ្រើសរើសគំរោងល្អៗរបស់ប្រទេសនីមួយៗ។ ដោយប្រទេសកម្ពុជាដាក់ចូលគំរោងជាច្រើន ប៉ុន្តែបានជាប់គំរោងពី២ ទី១-គឺបានទៅលើខេត្តបាត់ដំបងដែលមានផ្លូវចេញចូលតែមួយច្រកតែមួយ និងគំរោងទី២-គឺជាគំរោងអភិវឌ្ឍន៍ល្អរបស់សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ ដែលត្រូវគណៈប្រតិភូទីក្រុង Bacolod ប្រទេសហ្វីលីពីនមករៀនសូត្រនិងអនុវត្តតាមនិងដើម្បីផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមកអំពីគំរោងភាពជាដៃគូរវាងប្រជាពលរដ្ឋវិស័យឯកជន រដ្ឋបាលមូលដ្ឋាននិងរដ្ឋព្រោះនៅប្រទេសយើងបានអនុវត្តជោគជ័យលើគំរោងទាំងនេះជាពិសេសនៅសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ ដែលនៅប្រទេសហ្វីលីពីនអនុវត្តមិនទាន់បានគឺអនុវត្តបានតែ២៣ចំណុចប៉ុណ្ណោះក្នុងចំណោមទីក្រុងដែលល្អជាងគេគឺទីក្រុង Bacolod នេះ។

ក្នុងជំនួបជាមួយប្រតិភូហ្វីលីពីននោះលោកសយ កុសលក៏បានធ្វើបទបង្ហាញដល់គណៈប្រតិភូរបស់ទីក្រុង Bacolod អំពីការអភិវឌ្ឍន៍រីកចំរើនលើគ្រប់វិស័យជាពិសេសទៅលើហេដ្ឋារចនាសម្ព័ន្ធដែលសង្កាត់បានអនុវត្តជោគជ័យក្នុងរយៈពេលខ្លីដែលមានក្រុមប្រឹក្សាចំនួនតិចប៉ុន្តែអនុវត្តបានល្អគួរជាទីមោទនភាពបំផុត។ លោកបានបន្តទៀតថាកត្តាជំរុញឱ្យមានបទពិសោធន៍ល្អសង្កាត់ទួលសង្កែបានពង្រីកនិងប្រើប្រាស់យន្តការផែនការនិងធ្វើថវិកាដើម្បីកៀរគរធនធានពីប្រជាពលរដ្ឋអ្នករកស៊ីធំៗនិងម្ចាស់ ក្រុមហ៊ុនរោងចក្រដើម្បីយកមកកសាងហេដ្ឋារចនាសម្ព័ន្ធព្រមទាំងសកម្មភាពធំបងៗនិងបានបង្កើតគណៈកម្មាធិការផែនការនិងថវិកាគណៈកម្មការគ្រប់គ្រងគំរោងក្រុមការងារសិក្សាផលប៉ះពាល់សំរាប់ផ្សព្វផ្សាយកៀរគរធនធានគ្រប់គ្រងការដេញថ្លៃ(គណៈកម្មការលទ្ធកម្ម) គ្រប់គ្រងគំរោងនិងធ្វើការត្រួតពិនិត្យលើគំរោងជាប្រចាំ។ ការជូនដំណឹងនិងចេញវិក្កយបត្រដល់ប្រជាពលរដ្ឋអំពីការចូលរួមនិងបិទព័ត៌មានអំពីការចូលរួមនៅតាមផ្ទះនិងនៅទីសាធារណៈ។

លោកបន្តថា ប្រជាពលរដ្ឋនិងអង្គការមិនមែនរដ្ឋាភិបាលក៏បានចូលរួមក្នុងការធ្វើផែនការអនុវត្តគំរោងតាមដាននិងដោះស្រាយទំនាស់ក្នុងពេលអនុវត្តក្នុងការថែរក្សា ហើយលទ្ធផលក្រុមប្រឹក្សាសង្កាត់បានកសាងនូវហេដ្ឋារចនាសម្ព័ន្ធសង្គមរួមមានផ្លូវកៅស៊ូ ផ្លូវថ្មក់បេតុង ប្រព័ន្ធលូ លូបង្ហូរទឹកប្រឡាយ និងជួលជុលជាប្រចាំនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធនិងសមិទ្ធផលទាំងអស់នោះ។ លោកបន្តថាគិតមកដល់ឆ្នាំ២០១១នេះនៅក្នុងមូលដ្ឋានសង្កាត់ទួលសង្កែបានប្រែក្លាយផ្លូវដីមកជាផ្លូវកៅស៊ូ ផ្លូវបេតុងបានចំនួន៧០ភាគរយហើយដោយមិនដែលលិចទឹកនៅក្នុងរដូវវស្សាហើយថវិកាដែលប្រមូលបានក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះដើម្បីកែលំអនិងកសាងបន្ថែមមានចំនួន១៥០ម៉ឺនដុល្លារដែលប្រាក់ទាំងនោះគឺបានមកពីការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំខណ្ឌក៏ដូចជាសង្កាត់បានកៀរគរដល់ផ្នែកឯកជននិងសប្បុរសជនឱ្យជួយដល់មូលដ្ឋានក្នុងនោះមានចំនួន៨០ភាគរយដែលឧបត្ថម្ភដោយផ្នែកឯកជននិងសប្បុរសជន។

លោកសយ កុសលក៏បានឱ្យដឹងថាប្រជាពលរដ្ឋក្នុងសង្កាត់ទួលសង្កែភាគច្រើនពីមុនធ្វើស្រែចំការប៉ុន្តែមកដល់ប៉ុន្មានឆ្នាំចុងក្រោយនេះបានប្តូរមកធ្វើសេវាកម្មវិញនិងផ្ទៃដីមួយចំនួនធំក្លាយជារោងចក្រឧស្សាហកម្មនិងលំនៅដ្ឋានទាំងស្រុងហើយរោងចក្រនៅក្នុងសង្កាត់នេះបច្ចុប្បន្នមានចំនួន៣៨រោងចក្រ។ ចំណុចសំខាន់ដែលក្រុមប្រឹក្សាទទួលបានជោគជ័យនោះគឺកំណត់ការទទួលខុសត្រូវមានផែនការជាក់លាក់និងថវិកាដែលអាចបត់បែនបានពីមួយស្ពាល់និងមួយទៀតជៀជាក់។

នៅឱកាសនោះលោកសយ កុសលក៏បាននាំគណៈប្រតិភូរបស់ទីក្រុង Bacolod ទៅជួបសិក្សាប្តូរយោបល់ជាមួយប្រជាពលរដ្ឋវិស័យឯកជននិងរោងចក្រសហគ្រាសដែលសហការល្អកន្លងមកធ្វើឱ្យសង្កាត់មានការអភិវឌ្ឍន៍ទទួលបានជោគជ័យ។

គណៈប្រតិភូដែលដឹកនាំដោយលោកអភិបាលក្រុង Bacolod ក៏បានធ្វើបង្ហាញឱ្យក្រុមប្រឹក្សាសង្កាត់ទួលសង្កែបានយល់អំពីការរីកចំរើនលើគ្រប់វិស័យរបស់ទីក្រុងរបស់គេផងដែរ។ លោកក៏បានឱ្យដឹងថាទីក្រុងក្នុងប្រទេសហ្វីលីពីនទាំងអស់មាន១២២ហើយគេបានបោះឆ្នោតជ្រើសរើសយកទីក្រុងដែលអភិវឌ្ឍន៍ល្អទីក្រុងដែលមានហេដ្ឋារចនាសម្ព័ន្ធល្អហើយក៏បានបោះឆ្នោតជាប់ទីក្រុង Bacolod ហើយលោកអភិបាលក្រុងក៏មើលឃើញប្រទេសកម្ពុជាដែលត្រូវមករៀនសូត្រតាមអំពីគំរោងល្អៗជាពិសេសភាពជាដៃគូរវាងពលរដ្ឋវិស័យឯកជនរដ្ឋបាលមូលដ្ឋាននិងរដ្ឋជាពិសេសទីក្រុង Bacolod នេះមិនទាន់អនុវត្តបានជោគជ័យនៅឡើយ។

លោកអភិបាលក្រុងរូបនោះបន្តថាទីក្រុង Bacolod បានរីកចំរើនជាងគេក្នុងចំណោម១២២ក្នុងប្រទេសលើផ្នែកសេដ្ឋកិច្ច ឧស្សាហកម្មរ៉ែគ្រប់គ្រងគ្រោះមហន្តរាយនិងជាពិសេសគឺមានអូតែលច្រើនជាងគេហើយរវាងប្រជាជនសហគ្រាសឯកជនអាជ្ញាធរមូលដ្ឋានរដ្ឋគឺសហការគ្នាបានល្អ។ ទីបញ្ចប់គណៈប្រតិភូរបស់ទីក្រុង Bacolod និងក្រុមប្រឹក្សាសង្កាត់ទួលសង្កែក៏បានផ្លាស់ប្តូរនូវវត្ថុអនុស្សាវរីយ៍ទៅវិញទៅមកមុននឹងបញ្ចប់ទស្សនកិច្ចសិក្សានេះ។

ឆីទៀ